ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៣៣ សហវ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**
**ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ១២០ សហវ ប្រក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការកែសម្រួល ប្រកាស លេខ ២១៨ សហវ ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើត គណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងលើភាពចាំបាច់របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# **សម្រេច**

**ប្រការ១**.-

បង្កើត "**ក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស**" ហៅកាត់ " **កគជ** " ជាសេនាធិការនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងជាចំណុចប្រមូលផ្តុំសម្រាប់ការគ្រប់គ្រងជំនួយបច្ចេកទេសក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**ប្រការ២**.-

" **កគជ** " មានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| - អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| - ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារ កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | អនុប្រធានប្រចាំការ |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានចំណុះក្រសួង ឬតំណាង | សមាជិក |
| - អគ្គាធិការនៃអគ្គាធិការដ្ឋាន | សមាជិក |
| - ប្រធាននាយកដ្ឋានចំណុះក្រសួង | សមាជិក |
| - នាយកវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - ប្រធានអង្គភាពគ្រប់គ្រងសាច់ប្រាក់ | សមាជិក |

**ប្រការ៣**. –

"**កគជ** " មានភារកិច្ចគ្រប់គ្រង និងសម្របសម្រួលការប្រើប្រាស់ជំនួយបច្ចេកទេស ឲ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ដើម្បីគាំទ្រដល់ការរៀបចំ និងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងត្រូវបំពេញតួនាទី ការទទួលខុសត្រូវ ព្រមទាំងទទួលសិទ្ធិអំណាច ដូចមានចែងក្នុងលក្ខខណ្ឌយោងនៃក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ៤.** –

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០១០

គាត ឈន់

**ចំលងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាព ចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ
# នៃ
# សេចក្តីសម្រេចលេខ: ០៣៣ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១០ ស្តីពីការបង្កើត
# ក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស

## កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណ:

## លក្ខខណ្ឌយោង

## ក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស

នៅក្នុងដំណាក់កាលទី២នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាមទារអោយមានការកំណត់យុទ្ធសាស្រ្តដ៏ជាក់លាក់ ដើម្បីគាំទ្រ និងបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការគ្រប់គ្រង និងប្រើប្រាស់ជំនួយបច្ចេកទេសអោយចំទិសដៅ និងទាន់ពេលវេលា។ ដើម្បីសម្រេចយុទ្ធសាស្រ្តនេះ ទាមទារអោយមានការបង្កើតក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស។ ក្រុមការងារនេះដឹកនាំដោយអគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានប្រធានលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាអនុប្រធានប្រចាំការ និងអគ្គនាយកនៃអគ្គនាយកដ្ឋាន រឺតំណាងអគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋាន នាយកវិទ្យាស្ថាន ប្រធានអង្គភាព នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក ។

### I. តួនាទី

១- ជាចំណុចប្រមូលផ្តុំសម្រាប់ការគ្រប់គ្រងជំនួយបច្ចេកទេស / អ្នកជំនាញការនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីផ្សេងទៀត ។

២- ពិនិត្យ និងសម្រេចលើសំណើសុំជំនួយបច្ចេកទេស / អ្នកជំនាញការរបស់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋាន វិទ្យាស្ថាន អង្គភាព របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ។

៣-ធ្វើអាទិភាពភាវូនីយកម្មតម្រូវការជំនួយបច្ចេកទេស / អ្នកជំនាញការ សម្រាប់អគ្គនាយកដ្ឋាន អគ្គាធិការ-ដ្ឋាន នាយកដ្ឋាន វិទ្យាស្ថាន អង្គភាព របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន និងឈានទៅរៀបចំផែនការលទ្ធកម្ម នៃជំនួយបច្ចេកទេស / អ្នកជំនាញការសម្រាប់ឆ្នាំ និងឆ្នាំបន្តបន្ទាប់ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

៤- ពិនិត្យ និងសម្រេចលើលក្ខខណ្ឌយោងនៃអ្នកជំនាញការ/ គម្រោងស្នើសុំជំនួយបច្ចេកទេស ។

៥- ដឹកនាំការជ្រើសរើសអ្នកជំនាញការ /ចរចារសម្រាប់ជំនួយបច្ចេកទេស នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

៦- ត្រួតពិនិត្យការអនុវត្តរបស់អ្នកជំនាញការ/ជំនួយបច្ចេកទេស ។

៧- អនុម័តជាគោលការណ៍លើការងារទូទាត់ថវិកាជូនអ្នកជំនាញការ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

៨- ដឹកនាំដើម្បីពិនិត្យ និងសម្រេចលើការបន្តកិច្ចសន្យាសម្រាប់អ្នកជំនាញការ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

## II. **ការទទួលខុសត្រូវ**

១- គាំទ្រ និងបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការគ្រប់គ្រង និងប្រើប្រាស់ជំនាញការ / ជំនួយបច្ចេកទេសអោយចំទិសដៅ និងទាន់ពេលវេលា ។

២- ជំរុញ អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន វិទ្យាស្ថាន នាយកដ្ឋាន អង្គភាព នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្តល់យោបល់លើរបាយការណ៍របស់ជំនាញការ/ជំនួយបច្ចេកទេស អោយទាន់ពេលវេលា ។

៣- សហការជាមួយក្រុមសម្របសម្រួលក្រសួង-ស្ថាប័ន ដើម្បីធានាប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការគ្រប់គ្រង និងប្រើប្រាស់ជំនាញការ/ជំនួយបច្ចេកទេស ។

## III. **សិទ្ធិអំណាច**

១- អញ្ជើញអនុប្រធានប្រចាំ និងសមាជិក ចូលរួមប្រជុំតាមការចាំបាច់ ។

២- ស្នើសុំប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីលុបចោលកិច្ចសន្យារបស់អ្នកជំនាញការក្នុងករណីដែលអ្នកជំនាញការមិនគោរពតាមកិច្ចសន្យា ។

៣- ពិនិត្យ និងកំណត់អ្នកធ្វើការផ្ទាល់ជាមួយអ្នកជំនាញការ /ជំនួយបច្ចេកទេស នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

*******